01027688

E306/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 09 / 2014
ម៉ោង (Time/Heure): 09:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យ៉ា សុខន**
ចៅក្រម Claudia FENZ
ចៅក្រម **យូ អុត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងយុត្តាធិការ ទៅលើការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់សំណើស្នើសុំលប់ចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ[1]។ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានឆ្លើយតបនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១[2]។ នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយទៅលើសំណើសុំនេះដោយផ្នែក ប៉ុន្តែមិនបានសម្រេចទៅលើការលើកឡើងរបស់ អៀង សារី ដែលថាកថាខណ្ឌ ១៣៩៧ ដល់ ១៤០១ នៃដីកាដំណោះស្រាយដែលចោទប្រកាន់ពីការនិរទេសជនជាតិវៀតណាម "នៅព្រៃវែង, ស្វាយរៀង និងនៅសហករណ៍ត្រាំកក់" មានវិការនោះទេ[3]។ នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានអញ្ជើញភាគីផ្សេងទៀតឱ្យបញ្ជាក់ថាតើពួកគេយល់ស្របតាមការជំទាស់ដែលបានលើកឡើងដោយមេធាវីការពារក្តី អៀង សារី ដែរឬទេ[4]។ ក្រុមមេធាវីការពារក្តីទាំងពីរក្រុមបានដាក់សារណានៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤[5]

---

[1] សំណើរបស់អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី ឯកសារ E58 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ ដាក់ចូលក្នុងសំណុំរឿងថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សំណើរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ")

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសផ្នែកនីតិវិធី ឯកសារE58/1 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១។

[3] សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារE100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ (សម្រេចថាទម្រង់ជាមូលដ្ឋាន និងទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម អាចអនុវត្តបានចំពោះសំណុំរឿង ០០២ ហើយយល់ឃើញថា ទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម មិនបង្កើតឱ្យបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ហើយទម្រង់នេះក៏មិនមែនជាគោលការណ៍ទូទៅនៃច្បាប់ នៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ឡើយ។ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ឯកសារ E122 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ (សម្រេចថាអង្គជំនុំជម្រះបានទទួលសំណុំរឿង ដែលពុំមានសុពលភាពពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានា តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដូចមានរៀបរាប់ក្នុងផ្នែកសេចក្តីសម្រេចបញ្ចប់ត្រង់កថាខណ្ឌ ១៦១៣ នៃដីកាដំណោះស្រាយ)។ សូមមើលផងដែរ សំណើរបស់អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ កថាខណ្ឌ ១១ (ក.ស.ច.ស មិនមានយុត្តាធិការស៊ើបអង្កេតលើការនិរទេសរបស់ជនជាតិវៀតណាមក្នុងខេត្តព្រៃវែង ស្វាយរៀង និងក្នុងសហករណ៍ស្រុកត្រាំកក់ឡើយ ដូច្នេះ កថាខណ្ឌក្នុងដីកាដំណោះស្រាយចាប់ពី ១៣៩៧ ដល់ ១៤០១ ត្រូវតែលុបចោល")។

[4] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់" ឯកសារ E306 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ("អនុស្សរណៈថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤")។ នៅក្នុងអនុស្សរណៈថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានសម្រេចដោះស្រាយអញ្ញត្រកម្មចំនួនពីរគឺ៖ អាជ្ញាយុកាលនៃបទល្មើសការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងយុត្តិធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការនិរទេស។

ហើយការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៤[6]។

## ២. សារណា

២. មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះមិនមានយុត្តាធិការលើការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះទេ[7]។ មេធាវីការពារក្តី លើកឡើងបែបនេះដោយផ្អែកលើវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ដែលចែងថា សហចៅក្រមស៊ើប អង្កេត ត្រូវធ្វើការស៊ើបអង្កេតតែទៅលើអង្គហេតុ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរប៉ុណ្ណោះ[8]។ មេធាវីការពារក្តីបានលើកឡើងថា ការចោទប្រកាន់អំពីការនិរទេសជនជាតិ វៀតណាម ចេញពីខេត្តព្រៃវែង ស្វាយរៀង និងពីសហករណ៍ស្រុកត្រាំកក់ មិនមាននៅក្នុងដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ។ ការផ្លាស់ទីលំនៅដោយបង្ខំត្រូវបានចោទប្រកាន់ទាក់ទង ទៅនឹងប្រជាជនជារួម មិនមែនទៅលើតែជនជាតិវៀតណាមជាក់លាក់នោះឡើយ ហើយក៏មិនពាក់ ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនទៅប្រទេសវៀតណាមឡើយ[9]។ ហេតុនេះ មេធាវីការពារក្តី ខៀវ

---

អង្គជំនុំជម្រះនឹងដោះស្រាយទៅលើសារណារបស់ភាគី ចំពោះបញ្ហាអាជ្ញាយុកាលនៃបទល្មើសការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅ លើអនុសញ្ញាទីក្រុងហ្សឺណែវ ផ្សេងពីគ្នា។

[5] សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ ឯកសារE306/2 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ("សារណារបស់ ខៀវ សំផន")។ ជំហរទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ដែល លើកឡើងដោយក្រុមមេធាវីការពារ អៀង សារី ឯកសារE306/1 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ("សារណារបស់ នួន ជា")។

[6] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផនស្តីពីអញ្ញត្រកម្ម ឯកសារE306/4 ចុះថ្ងៃ ទី ០២ ខែ មិថុនា ឆ្នាំ ២០១៤ ("ចម្លើយតបរបស់ ក.ស.ព")។

[7] សារណារបស់ ខៀវ សំផន កថាខណ្ឌ ២១។

[8] សារណារបស់ ខៀវ សំផន កថាខណ្ឌ ១៩។

[9] សារណារបស់ ខៀវ សំផន កថាខណ្ឌ ១៦ ដល់ ១៨។ អង្គជំនុំជម្រះកត់សម្គាល់ថា ខៀវ សំផន យោងទៅលើ "[...] ដំណាក់ កាលលើកទីបីនៅខេត្តព្រៃវែង និងស្វាយរៀង [...]" សារណារបស់ ខៀវ សំផន កថាខណ្ឌ ១៦។ ក៏ប៉ុន្តែនៅក្រោយមក ខៀវ សំផន យោងទៅរក "[...] ការនិរទេសជនជាតិវៀតណាម នៅខេត្តព្រៃវែង ស្វាយរៀង និងនៅសហករណ៍ស្រុកត្រាំកក់ [...]" សារណារបស់ ខៀវ សំផន, កថាខណ្ឌ ១៨។ អង្គជំនុំជម្រះកត់សម្គាល់ថា សារណាមិនច្បាស់លាស់ត្រង់ថា តើមេធាវី ការពារក្តីយោងទៅរកការចោទប្រកាន់ពីការនិរទេស ពីទីកន្លែងទាំងនោះ ឬទៅទីកន្លែងទាំងនោះ ឬនៅក្នុងទីកន្លែងទាំងនោះ ប៉ុន្តែ អង្គជំនុំជម្រះបកស្រាយថាការលើកឡើងដែលបានបង្ហាញខាងលើ គឺសំដៅទៅលើការចោទប្រកាន់ពីការនិរទេសពីទីកន្លែងទាំង នោះ។

សំផន បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេតទៅលើអង្គហេតុទាំងអស់នេះឡើយ ហើយការដាក់បញ្ចូលអង្គហេតុនៃការនិរទេសបន្ទាប់មកនៅក្នុងកថាខណ្ឌ ១៣៩៧ ដល់ ១៤០១ នៃដីកាដំណោះស្រាយ គួរត្រូវបានប្រកាសថាមោឃៈ[10]។

៣. មេធាវីការពារក្តី នួន ជា មិនបានរក្សាទុកអញ្ញត្រកម្មរបស់ខ្លួន ទាក់ទិននឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ[11]។

៤. ក.ស.ព បានឆ្លើយតបថា សហចៅក្រមស៊ើបអង្កេត ពិតជាមានយុត្តាធិការទៅលើអង្គហេតុនៃការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជាប់ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅដោយបង្ខំទៅលើប្រជាជនមកពីខេត្តព្រៃវែង ស្វាយរៀង និងសហករណ៍ស្រុកត្រាំកក់[12] ហើយទាំង ក.ស.ព ក៏ដូចជាសហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការផ្លាស់ទីលំនៅដោយបង្ខំទៅលើប្រជាជន មិនមែនជា "អង្គហេតុថ្មី" តាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង ដែលត្រូវអានគួបនឹងមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡើយ[13]។ ក.ស.ព បានលើកឡើងបន្ថែមទៀតថា បណ្តឹងនៅពេលជំនុំជម្រះ ទាក់ទងការចោទប្រកាន់ពីវិការនីតិវិធី នៅក្នុងដីកាដំណោះស្រាយ ត្រូវបានហាមឃាត់យ៉ាងជាក់ច្បាស់ដោយវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង[14]។

## ៣. សម្អាងហេតុ

៥. វិធាន ៧៦(៧) ចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលឡើយ"[15]។ អនុលោមតាមវិធាននេះ ការជំទាស់ដែលបានលើកឡើងក្នុងពេលឥឡូវនេះ គួរត្រូវបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ក្នុងដំណាក់កាលស៊ើបអង្កេត។

---

[10] សារណារបស់ ខៀវ សំផន កថាខណ្ឌ ១៤, ១៨ និង ២០។

[11] សារណារបស់ នួន ជា កថាខណ្ឌ ១។

[12] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២៩។

[13] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៦។

[14] ដូចជើងទំព័រខាងលើ។

[15] សូមមើលផងដែរ សេចក្តីសម្រេចលើសំណើសុំរបស់ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, ឯកសារ E82, ឯកសារ E88 និងឯកសារ E92) អង្គជំនុំជម្រះតុលាការកំពូល ឯកសារ E116/1/7 កថាខណ្ឌ ៣១។

៦. ក៏ប៉ុន្តែ នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន អង្គជំនុំជម្រះបានពិចារណាទៅលើការជំទាស់ផ្នែកនីតិវិធី ដែលមានសំអាងហេតុជាក់លាក់ ទាក់ទងការចោទប្រកាន់ពីភាពមិនប្រក្រតីដែលបានកើតឡើងក្នុងអំឡុងពេលមុនជំនុំជម្រះ "ក្នុងករណីភាគីអាចបង្ហាញថា ពួកគាត់មិនមានឱកាសក្នុងការរកឱ្យឃើញនូវការក្លែងបន្លំ ដែលត្រូវបានចោទប្រកាន់នៅមុនពេលបើកសវនាការលើអង្គសេចក្តី ចំពោះសេចក្តីថ្លែងការណ៍ណាមួយដែលខុសពីកំណត់ហេតុនៃកិច្ចសម្ភាសន៍នៅដំណាក់កាលស៊ើបសួរ ឬក្នុងករណីមានភាពចាំបាច់ដើម្បីគាំពារភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី"[16]។

៧. អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី ខៀវ សំផន អាចចូលពិនិត្យមើលសំណុំរឿងទាំងមូល ហើយបានទទួលការជូនដំណឹងអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២។ ចាប់តាំងពីដើមដំបូងនៃសំណុំរឿង និងជាពិសេសចាប់តាំងពីចាប់ផ្តើមកិច្ចស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេត ឱ្យស៊ើបអង្កេតលើការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[17]។ នៅក្នុងពេលបង្ហាញខ្លួនជាលើកដំបូងរបស់ ខៀវ សំផន និង នួន ជា នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ពួកគេទាំងពីរត្រូវបានជូនដំណឹងជាផ្លូវការថា អំពើដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវទទួលការកំណត់ប្រភេទនៃបទចោទ ដែលរួមមាន "ការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[18]។

៨. អង្គជំនុំជម្រះកត់សម្គាល់ថា ក.ស.ព បានយោងយ៉ាងច្បាស់លាស់នៅក្នុងដីកាសន្និដ្ឋានស្ថាពរអំពីការនិរទេសជនជាតិវៀតណាម[19]។ បន្ថែមពីលើនេះ ការពិនិត្យមើលទៅលើដីកាដំណោះស្រាយ

---

[16] សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ឯកសារ E142/3 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៧។

[17] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ) យោងទៅលើកថាខណ្ឌ ៣៧ ដល់៤២។

[18] កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54។ កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ ខៀវ សំផន ឯកសារ D42 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[19] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ឯកសារ D390 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០, កថាខណ្ឌ ៧៨៨, ៧៩០, ៧៩៨, ៨០៨, ៨១៥, ៩៤៥,១២៦៣, ១៣៥៣, ១៣៦១ (ដោយយោងទៅលើប្រជាជនដែលជាប់សែស្រឡាយវៀតណាម ហើយរស់នៅក្នុងខេត្តព្រៃវែង ស្វាយរៀង និងស្រុកកំពង់លាំង ដែលត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅទៅប្រទេសវៀតណាម និងធ្វើការផ្លាស់ប្តូរគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងវៀតណាម ដោយផ្លាស់ប្តូរពីការនិរទេស

បង្ហាញថា ជនជាប់ចោទត្រូវបានចោទប្រកាន់ពីការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធទៅនឹងទីតាំងដែលត្រូវបានកំណត់អត្តសញ្ញាចំនួនបីគឺ៖ ព្រៃវែង, ស្វាយរៀង និងសហករណ៍ត្រាំកក់។ ដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់ថា "ប្រជាជនវៀតណាមក្នុងចំនួនដ៏ច្រើន ដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្ខំឱ្យចាកចេញពីទីកន្លែងដែលពួកគេកំពុងរស់នៅស្របច្បាប់ ហើយឆ្លងដែនទៅកាន់ប្រទេសវៀតណាម"[20]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ជនជាប់ចោទទទួលបានការជូនដំណឹងពីវិសាលភាពនៃកិច្ចស៊ើបសួរ និងជាពិសេសគឺឧក្រិដ្ឋកម្មនៃការនិរទេសប្រជាជនវៀតណាម ទៅប្រទេសវៀតណាម ដែលស្ថិតនៅក្នុងវិសាលភាពនេះដែរ។

៩. ហេតុដូច្នេះ ខៀវ សំផន មានឱកាសអាចរកឃើញភាពមិនប្រក្រតីដែលជាបញ្ហានៅពេលនេះ។ ប្រសិនបើវិសាលភាពនៃកិច្ចស៊ើបសួរ គឺជាបញ្ហានៃភាពចម្រូងចម្រាស បញ្ហានេះគួរតែត្រូវបានលើកឡើងនៅមុនពេលបើកសវនាការ។ យោងតាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានទទួលដីកាដំណោះស្រាយ ដែលត្រូវបានកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។

១០. មេធាវីការពារក្តី ខៀវ សំផន មិនបានបង្ហាញពីបញ្ហាចំពោះការជំនុំជម្រះប្រកបដោយយុត្តិធម៌បន្ថែមទៀត ដែលតម្រូវឱ្យមានការអន្តរាគមន៍ពីអង្គជំនុំជម្រះទេ នៅដំណាក់កាលនេះ។

**សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**សម្រេចបដិសេធ** សំណើសុំរបស់ ខៀវ សំផន។

ភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE * E.C.C.C * C.E.T.C *

**និល** ណុន

ទ្រង់ទ្រាយធំ ទៅជាការកម្ទេចទាំងស្រុង ហើយបានបញ្ជាក់ថាការនិរទេស និងការជម្លៀសប្រជាជននៅក្នុងព្រំដែនរដ្ឋមួយ ឬឆ្លងកាត់ព្រំដែនប្រទេស ត្រូវបានចាត់ទុកថាជា "អំពើធ្វើទុក្ខបុកម្នេញ")។

[20] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៩។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០។